ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ១២.០២០.២០៦...ស.ដ.ណ...

ថ្ងៃ សុក្រ ១៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០២០

## ជម្រាបមក
## លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា នៃបុគ្គលរាយការណ៍ទាំងអស់

**កម្មវត្ថុ ៖** របាយការណ៍របស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ស្តីពី ប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង និងប្រទេសដែលត្រូវបង្កើនការតាមដាន ។

**យោង ៖**
- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០
- ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨
- ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយ-ការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០
- លិខិតរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខធ១២.០២០.០៥៧ ស.ជ.ណ ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៦៦៣ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

យោងតាមលិខិតលេខធ១២.០២០.០៥៧ ស.ជ.ណ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានជូនដំណឹងអំពីការអនុវត្តវិធានការចំពោះប្រទេសដែលមានហានិភ័យខ្ពស់ និងមានចំណុចខ្វះខាតនៅក្នុងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ដូចមានចេញផ្សាយជាសាធារណៈរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

យោងតាមកិច្ចប្រជុំមហាសន្និបាតរបស់ FATF កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ កន្លងទៅនេះ FATF បានចេញផ្សាយរបាយការណ៍ស្តីពីប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង (High-Risk Jurisdictions Subject to a Call for Action) ដោយបានបន្តដាក់វិធានការប្រឆាំងនិងដាក់ទណ្ឌកម្មហិរញ្ញវត្ថុចំពោះសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ (ប្រទេសកូរ៉េ-ខាងជើង) ដោយសារប្រទេសនេះពុំបានបំពេញចំណុចខ្វះខាតនៃប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ខ្លួន ព្រមទាំងមានការគំរាមកំហែងនៃសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ក្នុងរបាយការណ៍នោះដែរ FATF ក៏បានបន្តដាក់វិធានការប្រឆាំងលើប្រទេសអ៊ីរ៉ង់ ដោយសារប្រទេសនេះមិនបានអនុវត្តតាមសន្ធិសញ្ញាប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងប៉ាឡឺម៉ូ (Palermo and Terrorist Financing Convention) ស្របតាម



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ស្តង់ដារបស់ FATF ដោយស្នើឱ្យប្រទេសជាសមាជិកទាំងអស់ បន្តអនុវត្តវិធានការប្រឆាំងលើប្រទេសអ៊ីរ៉ង់ស្របតាមអនុសាសន៍ទី១៩ (Recommendation 19) របស់ FATF។ (សូមមើលឧបសម្ព័ន្ធ ១ ឬគេហទំព័ររបស់ FATF: http://www.fatf-gafi.org/publications/high-risk-and-other-monitored-jurisdictions/documents/call-for-action-june-2020.html)។

អនុវត្តតាមខ្លឹមសារនៃកថាខណ្ឌ (គ) មាត្រា ១០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្រការ ២៧ នៃប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងប្រការ ២៤ នៃប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ស.ហ.ក ស្នើ លោក លោកស្រី ជំរុញការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំចំពោះទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការជាមួយ ឯកត្តបុគ្គល អាជីវកម្ម ក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុមកពីប្រទេសកូរ៉េ-ខាងជើង និងអ៊ីរ៉ង់ ព្រមទាំងស្វែងរកព័ត៌មានពីគោលបំណង ប្រវត្តិប្រតិបត្តិការ និងទំនាក់ទំនងអាជីវកម្ម ជាដើម ឱ្យបានលម្អិតជាលាយលក្ខ័អក្សរ និងបញ្ជូនមកអាជ្ញាធរមានសមត្ថកិច្ច។

ទន្ទឹមនេះ FAFT ក៏បានចេញផ្សាយបញ្ជីប្រទេសដែលត្រូវបង្កើនការតាមដាន (Jurisdictions under Increased Monitoring) ផងដែរ ដែលរួមមានប្រទេស៖ ១/. អាល់បានី (Albania), ២/. បាហាម៉ា (Bahamas) ៣/. បាបាដុស (Barbados), ៤/. បុតស្វាណា (Botswana), ៥/. ហ្គាណា (Ghana), ៦/. ហ្សាម៉ាអ៊ីក (Jamaica), ៧/. ម៉ូរីស (Mauritius), ៨/. មីយ៉ាន់ម៉ា (Myanmar), ៩/. នីការ៉ាហ្គា (Nicaragua), ១០/. ប៉ាគីស្ថាន (Pakistan), ១១/. ប៉ាណាម៉ា (Panama), ១២/. ស៊ីរី (Syria), ១៣/. អ៊ូហ្គង់ដា (Uganda), ១៤/. យេម៉ែន (Yemen), និង ១៥/. ស៊ីមបាវ៉េ (Zimbabwe)។ (សូមមើលឧបសម្ព័ន្ធ ២ ឬគេហទំព័ររបស់ FATF: http://www.fatf-gafi.org/publications/high-risk-and-other-monitored-jurisdictions/documents/increased-monitoring-june-2020.html)។ ដូច្នេះ សូម លោក លោកស្រី បន្តដាក់ប្រទេសដែលមានដូចក្នុងឧបសម្ព័ន្ធ ២ នេះ ទៅក្នុងដំណើរការវាយតម្លៃហានិភ័យរបស់គ្រឹះស្ថាន លោក លោកស្រី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា នៃបុគ្គលរាយការណ៍ទាំងអស់ អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**អគ្គលេខាធិការ**

ស.ហ.ក

**សាយ សំអាត**

# Appendix I

## High-Risk Jurisdictions subject to a Call for Action – 30 June 2020

High-risk jurisdictions have significant strategic deficiencies in their regimes to counter money laundering, terrorist financing, and financing of proliferation. For all countries identified as high-risk, the FATF calls on all members and urges all jurisdictions to apply enhanced due diligence, and in the most serious cases, countries are called upon to apply counter-measures to protect the international financial system from the ongoing money laundering, terrorist financing, and proliferation financing (ML/TF/PF) risks emanating from the country. This list is often externally referred to as the "black list".

On 28 April 2020, the FATF decided on a general pause in the review process for the list of high-risk jurisdictions subject to a call for action. Therefore, please refer to the list of High-Risk Jurisdictions subject to a Call for Action adopted in February 2020. While the statement may not necessarily reflect the most recent status in **Iran** and the **Democratic People's Republic of Korea's** AML/CFT regime, the FATF's call for action on these high-risk jurisdictions remains in effect.

- High-Risk Jurisdictions subject to a Call for Action – 21 February 2020
- FATF extends its assessment and follow-up deadlines in response to COVID-19

# Appendix II

## Jurisdictions under Increased Monitoring – 30 June 2020

Jurisdictions under increased monitoring are actively working with the FATF to address strategic deficiencies in their regimes to counter money laundering, terrorist financing, and proliferation financing. When the FATF places a jurisdiction under increased monitoring, it means the country has committed to resolve swiftly the identified strategic deficiencies within agreed timeframes and is subject to increased monitoring. This list is often externally referred to as the 'grey list'.

The FATF and FATF-style regional bodies (FSRBs) continue to work with the jurisdictions noted below and to report on the progress made in addressing the identified strategic deficiencies. The FATF calls on these jurisdictions to complete their agreed action plans expeditiously and within the proposed timeframes. The FATF welcomes their commitment and will closely monitor their progress. The FATF does not call for the application of enhanced due diligence to be applied to these jurisdictions, but encourages its members to take into account the information presented below in their risk analysis.

The FATF continues to identify additional jurisdictions, on an on-going basis, that have strategic deficiencies in their regimes to counter money laundering, terrorist financing, and proliferation financing. A number of jurisdictions have not yet been reviewed by the FATF and FSRBs.

On 28 April, the FATF decided on a general pause in the review process for the list of jurisdictions under increased monitoring,

- FATF extends its assessment and follow-up deadlines in response to COVID-19 (28 April 2020)

The FATF granted jurisdictions an additional four months for deadlines, with the exception of Mongolia and Iceland who requested to continue on their original schedule. As a result, the FATF reviewed and virtually met with only these jurisdictions and the result of these discussions is noted below.

**Iceland**

In October 2019, Iceland made a high-level political commitment to work with the FATF to strengthen the effectiveness of its AML/CFT regime and address any related technical deficiencies. The FATF has made the initial determination that Iceland has substantially completed its action plan and warrants an on-site assessment to verify that the implementation of Iceland's AML/CFT reforms has begun and is being sustained, and that the necessary political commitment remains in place to sustain implementation in the future. Specifically, Iceland has made the following key reforms: (1) ensuring the access to accurate basic and beneficial ownership information for legal persons by competent authorities in a timely manner; (2) introducing an automated system for STR filing and enhancing the FIU's capacity in its strategic and operational analysis; (3) ensuring implementation of TFS requirements among FIs and DNFBPs through effective supervision; and (4) enabling effective oversight and monitoring of NPOs with adequate resources and in line with the identified TF risks. The FATF will continue to monitor the COVID-19 situation and conduct an on-site visit at the earliest possible date.

**Mongolia**

In October 2019, Mongolia made a high-level political commitment to work with the FATF and APG to strengthen the effectiveness of its AML/CFT regime and address any related technical deficiencies. The FATF has made the initial determination that Mongolia has substantially completed its action plan and warrants an on-site assessment to verify that the implementation of Mongolia's AML/CFT reforms has begun and is being sustained, and that the necessary political commitment remains in place to sustain implementation in the future. Specifically, Mongolia has made the following key reforms: (1) improving sectoral ML/TF risk understanding by DNFBP supervisors, applying a risk-based approach to supervision and applying proportionate and dissuasive sanctions for breaches of AML/CFT obligations; (2)

demonstrating increased investigations and prosecutions of different types of ML activity in line with identified risks; (3) demonstrating further seizure and confiscation of falsely/non-declared currency and applying effective, proportionate and dissuasive sanctions; (4) demonstrating cooperation and coordination between authorities to prevent sanctions evasion; and (5) monitoring compliance by FIs and DNFBPs with their PF-related TFS obligations, including the application of proportionate and dissuasive sanctions. The FATF will continue to monitor the COVID-19 situation and conduct an on-site visit at the earliest possible date.

The statement on Jurisdictions under Increased Monitoring, adopted in February 2020 remains in effect for the remaining jurisdictions identified at that time:

- Albania
- The Bahamas
- Barbados
- Botswana
- Cambodia
- Ghana
- Jamaica
- Mauritius
- Myanmar
- Nicaragua
- Pakistan
- Panama
- Syria
- Uganda
- Yemen
- Zimbabwe

Please refer to the statement issued in February 2020 for details concerning each of these jurisdictions. However, please be advised that the statement may not necessarily reflect the most recent status in the jurisdiction's AML/CFT regime.